*ភ្នំពេញ , ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣*

# អនុក្រឹត្យលេខ ១២ អនក្រ

## ស្តីពី

## ការចាត់តាំងបង្កើតយោធភូមិភាគ

## និងតំបន់ប្រតិបត្តិការសឹក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការចាត់តាំង បង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់នាយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត ៦ យោធភូមិភាគ ដែលស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់អគ្គសេនាធិការ និងបង្កើតតំបន់ប្រតិបត្តិការសឹកចំនួន ២០ ចំណុះផ្ទាល់បណ្តាយោធភូមិភាគ ដែលមានភូមិសាស្ត្រទទួលខុសត្រូវដូចខាងក្រោម :

- *យោធភូមិភាគទី ១* : មានភារកិច្ចទទួលខុសត្រូវតំបន់ប្រតិបត្តិការសឹកចំនួន ៣ ដែលមានភូមិសាស្ត្រត្រូវនឹង :

១ - ខេត្ត ស្ទឹងត្រែង

២ - ខេត្ត រតនៈគិរី

៣ - ខេត្ត មណ្ឌលគិរី

និងកងឯកភាពទ័ពស្រួចចំណុះមួយចំនួន

- *យោធភូមិភាគទី ២* : មានភារកិច្ចទទួលខុសត្រូវ តំបន់ប្រតិបត្តិការសឹក ចំនួន ៤ ដែលមានភូមិសាស្ត្រត្រូវនឹង :

១ - ខេត្ត កំពង់ចាម

២ - ខេត្ត ព្រៃវែង

៣ - ខេត្ត ស្វាយរៀង

៤ - ខេត្ត ក្រចេះ

និងកងឯកភាពទ័ពស្រួចចំណុះមួយចំនួន

- *យោធភូមិភាគទី ៣* : មានភារកិច្ចទទួលខុសត្រូវតំបន់ប្រតិបត្តិការសឹកចំនួន ៥ ដែលមានភូមិសាស្ត្រត្រូវនឹង :

១ - ខេត្ត កំពង់ស្ពឺ

២ - ខេត្ត តាកែវ

៣ - ខេត្ត កំពត

៤ - ខេត្ត កោះកុង

៥ - ក្រុង ព្រះសីហនុ

និងកងឯកភាពទ័ពស្រួចចំណុះមួយចំនួន

- *យោធភូមិភាគទី ៤* : មានភារកិច្ចទទួលខុសត្រូវតំបន់ប្រតិបត្តិការសឹក ចំនួន ៣ ដែលមានភូមិសាស្ត្រត្រូវនឹង :

១ - ខេត្ត កំពង់ធំ

២ - ខេត្ត ព្រះវិហារ

៣ - ខេត្ត សៀមរាប-ឧត្តរមានជ័យ

និងកងឯកភាពទ័ពស្រួចចំណុះមួយចំនួន

- *យោធភូមិភាគទី ៥* : មានភារកិច្ចទទួលខុសត្រូវតំបន់ប្រតិបត្តិការសឹកចំនួន ៣ ដែលមានភូមិសាស្ត្រត្រូវនឹង :

១ - ខេត្ត បន្ទាយមានជ័យ

២ - ខេត្ត បាត់ដំបង

៣ - ខេត្ត ពោធិសាត់

និងកងឯកភាពទ័ពស្រួចចំណុះមួយចំនួន

- *យោធភូមិភាគពិសេស* : មានភារកិច្ចទទួលខុសត្រូវតំបន់ប្រតិបត្តិការសឹកចំនួន ២ ដែលមានភូមិសាស្ត្រត្រូវនឹងភូមិសាស្ត្រខេត្ត

១ - ខេត្ត កណ្ដាល

២ - ខេត្ត កំពង់ឆ្នាំង

និងកងឯកភាពទ័ពស្រួចចំណុះមួយចំនួន

**មាត្រា ២ :** ភារកិច្ចសិទ្ធិរចនាសម្ព័ន្ធចាត់តាំង និងចំនួនទីតាំងបញ្ជាការរបស់យោធភូមិភាគ និងតំបន់ប្រតិបត្តិការសឹកនីមួយៗ អាស្រ័យដោយអគ្គសេនាធិការកំណត់ជាក់ស្ដែង ។

**មាត្រា ៣ :** រដ្ឋមន្ត្រីខុទ្ទកាល័យទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្ថលេខា និងចុះហត្ថលេខានេះតទៅ ។

## រាជរដ្ឋាភិបាលកម្ពុជា

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| សម្ដេចក្រុមព្រះ **នរោត្ដម រណឫទ្ធិ** | ឯកឧត្តម **ហ៊ុន សែន** |

**********